# ថ្នាំអង់ទីប៊ីយ៉ូទិក ៖ តើថ្នាំអង់ទីប៊ីយ៉ូទិកគឺជាអ្វី ហើយគេប្រើវាដោយរបៀបណា

## ជំពូកទី ៧

នៅពេលដែលគេប្រើប្រាស់វាបានត្រឹមត្រូវ ថ្នាំអង់ទីប៊ីយ៉ូទិកគឺជាថ្នាំដែលមានសារប្រយោជន៍ និងមានសារសំខាន់យ៉ាងខ្លាំង ។ វាអាចប្រឆាំងនឹងការបង្ករោគ និងជំងឺដែលបង្កដោយ**បាក់តេរី**។ ថ្នាំអង់ទីប៊ីយ៉ូទិកដែលគេស្គាល់ជាញឹកញាប់គឺ ប៉េនីស៊ីលីន តេត្រាស៊ីគ្លីន ស្រ្តិបតូមីស៊ីន ខ្លរ៉ាំហ្វេនីកុល និងសុលហ្វា ឬស៊ុលហ្វូណាមីដ។

**ថ្នាំអង់ទីប៊ីយ៉ូទិកនីមួយៗមានឥទ្ធិពលខុសៗគ្នា ក្នុងការប្រឆាំងនឹងការបង្ករោគជាក់លាក់ផ្សេងៗគ្នា។ ថ្នាំអង់ទីប៊ីយ៉ូទិកទាំងអស់សុទ្ធតែមានគ្រោះថ្នាក់ក្នុងការប្រើប្រាស់ ប៉ុន្តែថ្នាំខ្លះមានគ្រោះថ្នាក់ខ្លាំងជាងថ្នាំខ្លះទៀត។ ប្រុងប្រយ័ត្នក្នុងការជ្រើសរើស និងប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិក។**

ថ្នាំអង់ទីប៊ីយ៉ូទិកមានច្រើនប្រភេទ ហើយប្រភេទនីមួយៗត្រូវបានដាក់លក់ក្រោម "ឈ្មោះពាណិជ្ជកម្ម" ជាច្រើន ដែលអាចធ្វើឲ្យមានការភ័ន្តច្រឡំ។ ទោះជាយ៉ាងនេះក៏ដោយ ថ្នាំអង់ទីប៊ីយ៉ូទិកដែលសំខាន់ជាងគេ ត្រូវបានចាត់ចូលក្នុងក្រុមចម្បងៗមួយចំនួន ៖

| **ក្រុមអង់ទីប៊ីយ៉ូទិក (ឈ្មោះវិទ្យាសាស្រ្ត)** | **ឧទាហរណ៍នៃឈ្មោះពាណិជ្ជកម្ម** | **ឈ្មោះពាណិជ្ជកម្ម នៅកម្ពុជា** | **មើលទំព័រ** |
|---|---|---|---|
| ប៉េនីស៊ីលីន ( Penicillin ) | *ប៉េន វេ-កា* | ហ្វេណុកស៊ីមេទីល ប៉េនីស៊ីលីន | ៣៥១ |
| អំពីស៊ីលីន ( Ampicillin ) | *ប៉េនប្រ៊ីទីន* | អំពីស៊ីលីន អំពីលីន អំពីស៊ីល | ៣៥៣ |
| តេត្រាស៊ីគ្លីន ( Tetracycline ) | *ទែរ៉ាមីស៊ីន* | តេត្រាស៊ីគ្លីន តេត្រាលីន | ៣៥៦ |
| ស៊ុលហ្វា ( ស៊ុលហ្វូណាមីដ sulfonamides ) | *ហ្គង់ទ្រីស៊ីន* | ឌុយ៉ាស៊ុលហ្វា សុកសាហ្សូល | ៣៥៨ |
| កូទ្រីម៉ុកហ្សាសូល ( Cotrimoxazole ) | *បាក់ទ្រីម* | កូទ្រីម | ៣៥៨ |
| ស្រ្តិបតូមីស៊ីន ( Streptomycin ) | *អំប៊ីសទ្រីន* | ឌុយផ្លូស្តូល | ៣៦៣, ៣៦៩ |
| ខ្លរ៉ាំហ្វេនីកុល ( Chloramphenicol ) | *ខ្លរ៉ូមីសេទីន* | ខ្លរ៉ាំមីសេទីន | ៣៥៧ |
| អេរីត្រូមីស៊ីន ( Erythromycin ) | *អេរីត្រូស៊ីន* | ភ្លាហ្វាណូន អីឡូសូន | ៣៥៥ |
| សេហ្វាឡូស្ពរីន ( Cephalosporins ) | *ខេហ្វ្លិច* | សេហ្វាឡិចស៊ីន | ៣៥៩ |

**កំណត់សំគាល់ ៖** អំពីស៊ីលីនជាប្រភេទមួយនៃក្រុមប៉េនីស៊ីលីន ដែលអាចសម្លាប់បាក់តេរីជាច្រើនប្រភេទជាងប៉េនីស៊ីលីនធម្មតា។

ប្រសិនបើអ្នកមានថ្នាំអង់ទីប៊ីយ៉ូទិកមួយ ដែលមានឈ្មោះពាណិជ្ជកម្មរបស់វា ហើយមិនដឹងថាវាស្ថិតនៅក្នុងក្រុមណានោះសូមអានអក្សរតូចៗ ដែលមាននៅលើប្រអប់ ឬដបថ្នាំនោះ។ ឧទាហរណ៍ ៖ បើអ្នកមានថ្នាំប៉ារ៉ាសាំង "អែស" ហើយអ្នកមិនដឹងថាវាជាថ្នាំអ្វី សូមមើលអក្សរតូចៗ ដែលសរសេរថា "ខ្លរ៉ាំហ្វេនីកុល ( Chloramphenicol )"។



សូមរកមើលខ្លរ៉ាំហ្វេនីកុលនៅទំព័រលៃតង ( ទំ.៣៥៧ )។ អ្នកនឹងដឹងថា គេប្រើវាតែក្នុងករណីជំងឺធ្ងន់មួយចំនួនប៉ុណ្ណោះ ដូចជាជំងឺគ្រុនពោះវៀន ហើយជាពិសេសគឺ វាមានគ្រោះថ្នាក់ បើប្រើជាមួយទារក។

**មិនត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិកណាមួយឡើយ លុះត្រាតែអ្នកស្គាល់ថាវាស្ថិតក្នុងក្រុមអ្វី វាប្រឆាំងនឹងជំងឺអ្វី និងការប្រុងប្រយ័ត្នដែលអ្នកត្រូវមាន ដើម្បីប្រើវាដោយសុវត្ថិភាព។**

ព័ត៌មានស្ដីអំពីការប្រើប្រាស់ កម្រិតប្រើ គ្រោះថ្នាក់និងការប្រុងប្រយ័ត្នសម្រាប់ថ្នាំអង់ទីប៊ីយ៉ូទិក ដែលបានណែនាំនៅក្នុងសៀវភៅនេះ អាចរកមើលនៅទំព័របៃតង។ អ្នកអាចរកមើលឈ្មោះថ្នាំទៅតាមលំដាប់ជួរព្យញ្ជនៈ ដែលមាននៅទំព័រដំបូងនៃទំព័របៃតង។

## សេចក្ដីណែនាំសម្រាប់ការប្រើថ្នាំអង់ទីប៊ីយ៉ូទិកគ្រប់ប្រភេទ

១. បើអ្នកមិនដឹងច្បាស់ពីរបៀបប្រើថ្នាំអង់ទីប៊ីយ៉ូទិក និងប្រភេទជំងឺដែលថ្នាំនោះអាចប្រឆាំងទេ សូមអ្នកកុំប្រើវាឲ្យសោះ។

២. ប្រើតែថ្នាំអង់ទីប៊ីយ៉ូទិកដែលត្រូវបានណែនាំសម្រាប់ជំងឺដែលអ្នកចង់ព្យាបាលនោះប៉ុណ្ណោះ (សូមរកមើលជំងឺផ្សេងៗ នៅក្នុងសៀវភៅនេះ)។

៣. ត្រូវស្គាល់ពីគ្រោះថ្នាក់ក្នុងការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិក និងប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នផ្សេងៗដែលបានណែនាំ(មើលនៅទំព័របៃតង)។

៤. ប្រើថ្នាំអង់ទីប៊ីយ៉ូទិកទៅតាមកម្រិតប្រើដែលបានណែនាំ ដោយមិនត្រូវប្រើលើសកម្រិត ឬប្រើមិនគ្រប់កម្រិត។ កម្រិតនៃការប្រើប្រាស់ថ្នាំគឺអាស្រ័យទៅតាមប្រភេទជំងឺ អាយុ ឬទម្ងន់របស់អ្នកជំងឺ។

៥. មិនត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិកចាក់ទេ បើការលេបតាមមាត់ទំនងជាមានប្រសិទ្ធភាពដូចគ្នានោះ។ ត្រូវចាក់តែនៅពេលដែលចាំបាច់ប៉ុណ្ណោះ។

៦. បន្តប្រើថ្នាំអង់ទីប៊ីយ៉ូទិករហូតទាល់តែជំងឺជាសះស្បើយទាំងស្រុង ឬត្រូវប្រើយ៉ាងតិចពីរថ្ងៃបន្ទាប់ពីគ្រុនក្ដៅ និងរោគសញ្ញានៃការបង្ករោគបានបាត់ទៅវិញ។ (ជំងឺមួយចំនួនដូចជាជំងឺរបេង និងជំងឺឃ្លង់ ត្រូវការការព្យាបាលជាច្រើនខែ ឬច្រើនឆ្នាំ បន្ទាប់ពីអ្នកជំងឺនោះមានការធូរស្រាល។ អនុវត្តតាមសេចក្ដីណែនាំចំពោះជំងឺនីមួយៗ)។

៧. បើថ្នាំអង់ទីប៊ីយ៉ូទិកបណ្ដាលឲ្យឡើងកន្ទួលលើស្បែក រមាស់ ពិបាកក្នុងការដកដង្ហើម ឬមានប្រតិកម្មធ្ងន់ធ្ងរ ឈប់ប្រើវាភ្លាម ហើយមិនត្រូវប្រើវាទៀតឡើយ (មើលទំ.៧០)។

៨. ប្រើថ្នាំអង់ទីប៊ីយ៉ូទិកតែនៅពេលដែលត្រូវការចាំបាច់បំផុតប៉ុណ្ណោះ។ នៅពេលដែលគេប្រើថ្នាំអង់ទីប៊ីយ៉ូទិកច្រើនពេក នោះប្រសិទ្ធភាពរបស់វានឹងចាប់ផ្ដើមថយចុះដែរ។

## សេចក្ដីណែនាំសម្រាប់ការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកប្រភេទខ្លះ

១. មុនពេលអ្នកចាក់ ថ្នាំប៉េនីស៊ីលីន ឬអំពីស៊ីលីន អ្នកត្រូវមានថ្នាំអំពូល អាដ្រេណាលីន (អេពីណេហ្វ្រីន epinephrine) ឲ្យហើយ សម្រាប់ព្យាបាលប្រតិកម្មអាល់ឡែស៊ី ប្រសិនបើវាកើតឡើង(ទំ.៧០)។

២. ចំពោះមនុស្សដែលអាល់ឡែស៊ីជាមួយប៉េនីស៊ីលីន ប្រើថ្នាំអង់ទីប៊ីយ៉ូទិកផ្សេងទៀតដូចជា៖ អេរីត្រូមីស៊ីន ឬស៊ុលហ្វា (ទំ.៣៥៥និង៣៥៨)។

៣. កុំប្រើថ្នាំ តេត្រាស៊ីគ្លីន អំពីស៊ីលីន ឬថ្នាំអង់ទីប៊ីយ៉ូទិកដែលមានឥទ្ធិពលទូលាយ ដើម្បីព្យាបាលជំងឺដែលអាចព្យាបាលដោយប្រើថ្នាំប៉េនីស៊ីលីន ឬថ្នាំអង់ទីប៊ីយ៉ូទិកផ្សេងទៀតដែលមានឥទ្ធិពលចង្អៀត(ទំ.៥៨)។ ថ្នាំអង់ទីប៊ីយ៉ូទិកដែលមានឥទ្ធិពលទូលាយ ប្រឆាំងនឹងបាក់តេរីច្រើនប្រភេទជាងថ្នាំអង់ទីប៊ីយ៉ូទិកដែលមានឥទ្ធិពលចង្អៀត។

៤. ជាទូទៅ គេប្រើថ្នាំខ្លរ៉ាំហ្វេនីកុលសម្រាប់តែជំងឺដែលធ្ងន់ធ្ងរ ឬដែលគំរាមកំហែងដល់អាយុជីវិត ដូចជាជំងឺគ្រុនពោះវៀន។ វាជាថ្នាំដែលមានគ្រោះថ្នាក់។ មិនត្រូវប្រើវាសម្រាប់ជំងឺស្រាលៗទេ។ និងមិនត្រូវប្រើវាជាមួយទារកដែរ(លើកលែងជំងឺក្អកមាន់ ទំ.៣១៣)។

៥. មិនត្រូវចាក់ថ្នាំតេត្រាស៊ីគ្លីន ឬខ្លរ៉ាំហ្វេនីកុលទេ។ ថ្នាំទាំងនេះមានសុវត្ថិភាព មិនសូវឈឺចាប់ ហើយមានប្រសិទ្ធភាពដូចគ្នាឬល្អជាង បើលេបតាមមាត់។

៦. មិនត្រូវឲ្យស្ត្រីមានផ្ទៃពោះ ឬកុមារដែលមានអាយុតិចជាង៨ឆ្នាំ ប្រើតេត្រាស៊ីគ្លីនទេ ព្រោះវាអាចធ្វើឲ្យខូចធ្មេញនិងឆ្អឹង(ទំ.៣៥៦)។

៧. ជាទូទៅ គេប្រើស្រ្តិបតូមីស៊ីននិងផលិតផលដែលមានជាតិថ្នាំនេះ សម្រាប់តែជំងឺរបេងប៉ុណ្ណោះ ហើយត្រូវប្រើជាមួយថ្នាំរបេងផ្សេងទៀត (ទំ.៣៥៣)។ ស្រ្តិបតូមីស៊ីនផ្សំជាមួយនឹងប៉េនីស៊ីលីនអាចប្រើសម្រាប់ព្យាបាលរបួសជ្រៅៗដល់ពោះវៀន រលាកខ្នែងពោះវៀន និងជំងឺផ្សេងទៀត នៅពេលដែលគេមិនអាចរកថ្នាំអំពីស៊ីលីនបាន ឬនៅពេលវាថ្លៃពេកនោះ។ ប៉ុន្តែមិនត្រូវ ប្រើសម្រាប់ព្យាបាលគ្រុនផ្តាសាយ ហៀរសំបោរ ឬជំងឺផ្លូវដង្ហើមដែលច្រើនកើតមាននោះឡើយ។

៨. ថ្នាំគ្រប់ប្រភេទដែលស្ថិតក្នុងក្រុមស្រ្តិបតូមីស៊ីន(រាប់បញ្ចូលទាំង កាណាមីស៊ីន(Kanamycin) និង ហ្សង់តាមីស៊ីន (Gentamycin) គឺអាចមានជាតិពុលច្រើន។ ជាញឹកញាប់ ថ្នាំទាំងនេះត្រូវបានគេប្រើវា សម្រាប់ព្យាបាលជំងឺស្រាលៗ ដែលក្នុងនោះវាអាចមានផលគ្រោះថ្នាក់ច្រើនជាងផលល្អ។ ប្រើថ្នាំទាំងនេះសម្រាប់ការបង្ករោគធ្ងន់ធ្ងរមួយចំនួន ដែលថ្នាំទាំងនេះត្រូវបានគេណែនាំឲ្យប្រើ។

៩. ការផឹកទឹកដោះគោជូរនិងទឹកដោះគោកក អាចជួយឲ្យមានការកើតបាក់តេរីដែលសំខាន់មួយចំនួន ដែលត្រូវបានសម្លាប់ដោយថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាថ្នាំអំពីស៊ីលីន និងធ្វើឲ្យលំនឹងធម្មជាតិរបស់រាងកាយ ត្រលប់មកសភាពធម្មតាវិញ(មើលទំព័របន្ទាប់)។

## តើត្រូវធ្វើដូចម្តេចបើថ្នាំអង់ទីប៊ីយ៉ូទិកហាក់ដូចជាពុំមានប្រសិទ្ធភាព

ចំពោះការបង្ករោគភាគច្រើន ថ្នាំអង់ទីប៊ីយ៉ូទិកចាប់ផ្តើមធ្វើឲ្យមានការធូរស្រាលក្នុងរយៈពេលមួយឬពីរថ្ងៃ។ **ប្រសិនបើថ្នាំអង់ទីប៊ីយ៉ូទិកដែលអ្នកប្រើនោះ ហាក់ដូចជាពុំមានប្រសិទ្ធភាពទេ វាអាចបណ្តាលមកពី ៖**

១. ជំងឺនោះពុំមែនជាជំងឺដែលអ្នកបានគិតនោះទេ។ អ្នកប្រហែលជាប្រើថ្នាំខុស។ ខិតខំស្វែងយល់ឲ្យកាន់តែច្បាស់ថាតើវាជាជំងឺអ្វីពិតប្រាកដ ដើម្បីប្រើថ្នាំឲ្យត្រូវនឹងជំងឺនោះ។

២. កម្រិតប្រើថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រឹមត្រូវ។ ពិនិត្យមើលឡើងវិញ។

៣. បាក់តេរីបានក្លាយជាមានភាពស៊ាំនឹងថ្នាំអង់ទីប៊ីយ៉ូទិកដែលប្រើនោះ(ថ្នាំនោះមិនអាចសម្លាប់មេរោគនោះបានទៀតទេ)។ ប្រើថ្នាំអង់ទីប៊ីយ៉ូទិកប្រភេទផ្សេងទៀតដែលត្រូវនឹងជំងឺនោះ។

៤. អ្នកពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការព្យាបាលជំងឺនោះ។ ប្រញាប់រកជំនួយពីគ្រូពេទ្យ ជាពិសេសបើជំងឺនោះមានសភាពធ្ងន់ធ្ងរ ឬកាន់តែធ្ងន់ធ្ងរ។

**កុមារទាំងបីនាក់នេះមានជំងឺគ្រុនផ្តាសាយ...**

*តើអ្វីធ្វើឲ្យកុមារស្លាប់?*



*ប៉េនីស៊ីលីន (មើលស្តុកអាល់ឡែស៊ី ទំ.៧០)*

*តើអ្វីសម្លាប់កុមារ?*



*ខ្ល័រំហ្វេនីកុល គ្រោះថ្នាក់ និងការប្រុងប្រយ័ត្នផ្សេងៗសម្រាប់ថ្នាំនេះ (ទំ.៣៥៧)*

*តើហេតុអ្វីបានជាកុមារនេះជាឡើងវិញ?*



*កុមារនេះពុំបានទទួលថ្នាំដែលមានគ្រោះថ្នាក់ គឺគ្រាន់តែទទួលទានទឹកផ្លែឈើ អាហារត្រឹមត្រូវ និងសម្រាកបានគ្រប់គ្រាន់។*

**ថ្នាំអង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពសម្រាប់ជំងឺគ្រុនផ្តាសាយទេ។ ប្រើថ្នាំអង់ទីប៊ីយ៉ូទិកសម្រាប់តែជំងឺដែលយើងដឹងថាវាត្រូវនឹងជំងឺនោះ។**

# សារសំខាន់នៃការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកដោយមានព្រំដែន

ការប្រើថ្នាំគ្រប់ប្រភេទ ត្រូវតែមានព្រំដែន ជាពិសេសចំពោះថ្នាំអង់ទីប៊ីយ៉ូទិក ដោយសារហេតុផលដូចខាងក្រោម ៖

១. **ការពុលនិងប្រតិកម្ម ៖** ថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រឹមតែអាចសម្លាប់បាក់តេរីប៉ុណ្ណោះទេ វាក៏អាចផ្តល់គ្រោះថ្នាក់ដល់ខ្លួនយើងបានដែរ ដោយសារវាអាចធ្វើឲ្យយើងពុល ឬអាចបណ្តាលឲ្យយើងមានប្រតិកម្មអាល់ឡែស៊ីបាន។ មនុស្សជាច្រើនបានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារគេប្រើថ្នាំអង់ទីប៊ីយ៉ូទិកដែលពួកគេមិនត្រូវការ។

២. **ការរំខានដល់លំនឹងធម្មជាតិ ៖** បាក់តេរីទាំងអស់ដែលនៅក្នុងខ្លួនយើងមិនមែនសុទ្ធតែផ្តល់គ្រោះថ្នាក់ទាំងអស់នោះទេ។ បាក់តេរីមួយចំនួនមានសារសំខាន់សម្រាប់ជួយឲ្យរាងកាយមានដំណើរការធម្មតាបាន។ ជាទូទៅថ្នាំអង់ទីប៊ីយ៉ូទិកសម្លាប់បាក់តេរីដែលមានប្រយោជន៍ក្នុងខ្លួនយើង ព្រមទាំងបាក់តេរីដែលបង្កគ្រោះថ្នាក់។ ជួនកាល ទារកដែលប្រើថ្នាំអង់ទីប៊ីយ៉ូទិក អាចមានការបង្ករោគនៅក្នុងមាត់(ជ្រាំង ទំ.២៣២) ឬនៅលើស្បែក (ម៉ូនីលីយ៉ាស៊ីស ទំ.២៤២) ដោយមេរោគផ្សិត។ បញ្ហានេះបណ្តាលមកពីថ្នាំអង់ទីប៊ីយ៉ូទិក បានសម្លាប់បាក់តេរីដែលជួយការពារមិនឲ្យមេរោគផ្សិតលូតលាស់នោះ។ ជាមួយមូលហេតុស្រដៀងគ្នានេះដែរ អ្នកដែលប្រើអំពីស៊ីលីន ឬពពួកថ្នាំអង់ទីប៊ីយ៉ូទិកដែលមានឥទ្ធិពលលំទូលាយដទៃទៀត ក្នុងរយៈពេលជាច្រើនថ្ងៃនឹងអាចបណ្តាលឲ្យមានរាក។ ថ្នាំអង់ទីប៊ីយ៉ូទិកអាចសម្លាប់ប្រភេទបាក់តេរីខ្លះដែលមានសារសំខាន់សម្រាប់ការរំលាយអាហារ ហើយធ្វើឲ្យមានការរំខានដល់លំនឹងធម្មជាតិនៃបាក់តេរីនៅក្នុងពោះវៀន។

៣. **ភាពស៊ាំទៅនឹងការព្យាបាល ៖** សម្រាប់រយៈពេលយូរអង្វែង ហេតុផលសំខាន់បំផុត ក្នុងការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកដោយមានព្រំដែននោះគឺថា **នៅពេលដែលថ្នាំអង់ទីប៊ីយ៉ូទិកត្រូវបានគេប្រើច្រើនពេក វានឹងក្លាយជាមិនសូវមានប្រសិទ្ធភាព។**

នៅពេលដែលមានការវាយប្រហារជាច្រើនដងដោយថ្នាំអង់ទីប៊ីយ៉ូទិកតែមួយ បាក់តេរីនឹងក្លាយទៅជាកាន់តែខ្លាំងហើយមិនស្លាប់ដោយសារថ្នាំនោះ។ ពួកវាក្លាយទៅជាស៊ាំនឹងថ្នាំអង់ទីប៊ីយ៉ូទិកនោះ។ ដោយហេតុនេះហើយបានជាជំងឺដែលប្រកបដោយគ្រោះថ្នាក់មួយចំនួន ដូចជាជំងឺគ្រុនពោះវៀន បានក្លាយទៅជាពិបាកព្យាបាលជាងកាលពីពីរបីឆ្នាំមុន។

នៅក្នុងតំបន់ខ្លះ ជំងឺគ្រុនពោះវៀនបានក្លាយជាស៊ាំទៅនឹងថ្នាំ ខ្ល័រហ្វេនីកុល ដែលតាមធម្មតាវាជាថ្នាំដែលមានប្រសិទ្ធភាពបំផុតសម្រាប់ព្យាបាលជំងឺនេះ។ ខ្ល័រហ្វេនីកុលត្រូវបានប្រើយ៉ាងច្រើនសម្រាប់ការបង្ករោគស្រាលៗ និងជាការបង្ករោគ ដែលក្នុងនោះ ការប្រើថ្នាំអង់ទីប៊ីយ៉ូទិកផ្សេងទៀតអាចមានសុវត្ថិភាពជាង និងមានប្រសិទ្ធភាពដូចគ្នា ឬជាការបង្ករោគ ដែលការព្យាបាលរបស់វា មិនត្រូវការថ្នាំអង់ទីប៊ីយ៉ូទិកទេ។

នៅទូទាំងពិភពលោក ជំងឺធ្ងន់ជាច្រើនបានស៊ាំនឹងថ្នាំអង់ទីប៊ីយ៉ូទិក ព្រោះគេបានប្រើវាយ៉ាងច្រើនលើសលប់សម្រាប់ព្យាបាលការបង្ករោគស្រាលៗ។ **បើចង់ឲ្យថ្នាំអង់ទីប៊ីយ៉ូទិកបន្តជួយជីវិតមនុស្សតទៅទៀត ការប្រើប្រាស់របស់វាត្រូវតែមានព្រំដែនកំណត់ជាងពេលបច្ចុប្បន្ន។** ការងារនេះគឺអាស្រ័យទៅលើការប្រើប្រាស់វាយ៉ាងត្រឹមត្រូវ ដោយវេជ្ជបណ្ឌិត បុគ្គលិកសុខាភិបាល និងប្រជាជនខ្លួនឯង។

ចំពោះជំងឺស្រាលៗភាគច្រើន ថ្នាំអង់ទីប៊ីយ៉ូទិកគឺមិនចាំបាច់ និងមិនគួរប្រើទេ។ គេអាចព្យាបាលជំងឺសើស្បែកស្រាលៗប្រកបដោយជោគជ័យ ដោយប្រើសាប៊ូនិងទឹក ឬត្រាំទឹកក្តៅ និងគេអាចលាបថ្នាំស្ងួន់ទីស៊ីយ៉ានវីយ៉ូឡេ (ទំ.៣៧១)។ ចំពោះជំងឺផ្លូវដង្ហើមស្រាលៗដូចជាគ្រុនផ្តាសាយ ហៀរសំបោ គេអាចព្យាបាលយ៉ាងមានប្រសិទ្ធភាពបំផុតដោយឲ្យផឹកទឹកឲ្យច្រើននិងបរិភោគអាហារដែលមានជីវជាតិ និងសម្រាកឲ្យបានគ្រប់គ្រាន់។ **ចំពោះជំងឺរាកជាច្រើនគេមិនចាំបាច់ប្រើថ្នាំអង់ទីប៊ីយ៉ូទិកឡើយ ព្រោះវាអាចធ្វើឲ្យមានគ្រោះថ្នាក់ទៅវិញទេ។** អ្វីដែលសំខាន់បំផុតនោះគឺត្រូវផឹកទឹកឲ្យបានច្រើន(ទំ.១៥៥) និងផ្តល់អាហារឲ្យបានគ្រប់គ្រាន់នៅពេលដែលកុមារអាចបរិភោគបាន។

**កុំប្រើថ្នាំអង់ទីប៊ីយ៉ូទិកសម្រាប់ជំងឺដែលខ្លួនយើងអាចប្រយុទ្ធដោយខ្លួនឯង ដោយជោគជ័យ។**
**ទុកវាសម្រាប់ប្រើនៅពេលដែលត្រូវការវាជាចាំបាច់។**